**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៤ ស.ស.រ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យស្រោចស្រពព្រះសុគន្ធវារី ថ្វាយសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៩១ យាងចូល ៩២ ព្រះវស្សា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** ៖ ត្រូវបានបង្កើតគណៈកម្មការរៀបចំបុណ្យស្រោចស្រពព្រះសុគន្ធវារីថ្វាយសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៩១ យាងចូល ៩២ ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ត្រូវនឹងថ្ងៃទី ១២កើត ខែទុតិយាសាឍ ព.ស ២៥៥៩ នៅវត្តបុទុមវតី រាជធានីភ្នំពេញ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម | **មិន ឃិន** | ប្រធាន |
| ២- ព្រះញាណវង្ស | **ឃឹម សន** | អនុប្រធាន |
| ៣- ឯកឧត្តម | **យូ ស៊ុនឡុង** | អនុប្រធាន |
| ៤- ឯកឧត្តម | **ចក្រី ចន្សុត** | អនុប្រធាន |
| ៥- ឯកឧត្តម | **ប៉ា សុជាតិវង្ស** | សមាជិក |
| ៦- ឯកឧត្តម | **ហ៊ុន ស៊ីថា** | សមាជិក |
| ៧- ឯកឧត្តម | **ឈិន កេតនា** | សមាជិក |
| ៨- ឯកឧត្តម | **ប្អូន លឹមហេង** | សមាជិក ។ |

**ប្រការ ២** ៖ គណៈកម្មាធិការនេះ មានមុខងារ និងភារកិច្ចរៀបចំពិធីបុណ្យ ដូចតទៅ៖

- សហការជាមួយក្រសួង-ស្ថាប័នពាក់ពន្ធ័ និងគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំពិធីបុណ្យស្រោចស្រពព្រះសុគន្ធវារី តាមប្រពៃណីព្រះពុទ្ធសាសនាឲ្យប្រព្រឹត្តទៅបានល្អប្រសើរ ។
- ពិនិត្យ និងលើកសំណើដោះស្រាយរាល់បញ្ហានានា ទាក់ទិននឹងការរៀបចំពិធីបុណ្យខាងលើ ។
- រៀបចំកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងពិធីបុណ្យឲ្យបានល្អប្រសើរ ។
- ធ្វើលិខិតអញ្ជើញ រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវដែលអញ្ជើញចូលរួម ។
- លើកគម្រោង និងចាត់ចែងគ្រប់គ្រងចំណូល-ចំណាយ អំពាវនាវសប្បុរសជន-សិស្សគណ ស្នើសុំវិភាគទានជាថវិកា និងសម្ភារៈបម្រើឲ្យពិធីបុណ្យប្រព្រឹត្តទៅបានរលូន និងល្អប្រសើរ ។
- បំពេញភារកិច្ចជាក់ស្តែងផ្សេងៗទៀត តាមការចាំបាច់សម្រាប់បម្រើឲ្យពិធីបុណ្យ ។

**ប្រការ ៣** ៖ គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារជំនាញបន្ថែមជាជំនួយការ តាមការចាំបាច់ ដើម្បីធានាឲ្យការរៀបចំបុណ្យនេះ ប្រព្រឹត្តទៅបានល្អតាមប្រពៃណីព្រះពុទ្ធសាសនា ។

**ប្រការ ៤** ៖ ប្រធានមានសិទ្ធអញ្ជើញសមាសភាពគណៈកម្មការរៀបចំពិធីបុណ្យ និងសមាសភាពពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ តាមការចាំបាច់ ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញក្នុងការដឹកនាំការងារ ស្របតាមការប្រគល់សិទ្ធិរបស់ប្រធាន ។

**ប្រការ ៥** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ០១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- សម្តេចព្រះអគ្គមហាសង្ឃរាជ ទេព វង្ស
- គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងធម្មការ និងសាសនា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- សាលារាជធានីភ្នំពេញ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ